**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៥៥ សហវ.ប្រក

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការការងារ ការសិក្សា និង ស្រាវជ្រាវ សំរាប់វិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករកម្ពុជា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ

-បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ/បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ **ក.ជ.គ**

-បានឃើញអនុក្រឹត្យលេខ ១៨/អនក្រ/បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា **វ.គ.ស.ក**

-បានឃើញប្រកាសលេខ ២៨៦ សហវ. ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលប្រចាំវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

-បានឃើញកំណត់ហេតុប្រជុំថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាភិបាលប្រចាំ **វ.គ.ស.ក**

-បានឃើញការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ :** តែងតាំង :

| | | |
|---|---|---|
| ១-ឯកឧត្តម **ទី នាយី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-លោកស្រី **ជុំ វ៉ានី** | អនុប្រធានក្រុមប្រឹក្សាភិបាល វ.គ.ស.ក អាណត្តិទី១ | អនុប្រធាន |
| ៣-លោក **គុយ លឹម** | អនុប្រធាន ក.ជ.គ អាណត្តិទី១ | សមាជិក |
| ៤-លោក **គាត ស៊្រី** | អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ៥-លោក **ឡុង អានិច្ចបូរា** | អនុប្រធាននាយកដ្ឋានបច្ចេកទេស អាជ្ញាធរសវនកម្មជាតិ | សមាជិក |
| ៦-លោក **ចៅ ហាក់** | អនុប្រធានការិយាល័យប្រមូលពន្ធនិងស្ថិតិ នាយកដ្ឋានពន្ធដារ | សមាជិក |
| ៧-លោក **អ៊ុក សារុន** | អនុប្រធានការិយាល័យសិក្សា និងជាសាស្ត្រាចារ្យនៅ ស.ភ.ន.វ.ស | សមាជិក |
| ៨-លោក **ព្រហ្ម សុផាន់ណា** | មន្ត្រីការិយាល័យគណនេយ្យ សាកលវិទ្យាល័យជាតិគ្រប់គ្រង | សមាជិក |
| ៩-កញ្ញា **ហេង ថាវី** | សាស្ត្រាចារ្យគណនេយ្យ សាកលវិទ្យាល័យបៀលប្រាយ | សមាជិក |
| ១០-លោក **ម៉ូ ថារិន** | មន្ត្រីក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក និងលេខាធិការអចិន្ត្រៃយ៍ |

ជាគណៈកម្មការការងារ ការសិក្សា និងការស្រាវជ្រាវ។

**ប្រការ ២ :** តួនាទីនិងភារៈកិច្ច របស់គណៈកម្មការ :

-សិក្សាស្រាវជ្រាវ ចងក្រងកម្មវិធីសិក្សាគណនេយ្យករជំនាញនិងសវនករប្រតិស្រុត

-ផ្លាស់ប្តូរទស្សនៈជាមួយប្រទេសដទៃ សហព័ន្ធគណនេយ្យករអន្តរជាតិ និងសហព័ន្ធគណនេយ្យករអាស៊ាន ដើម្បីធ្វើទំនើបកម្មកម្មវិធីសិក្សាគណនេយ្យករជំនាញនិងសវនករប្រតិស្រុត និងធ្វើការផ្សព្វផ្សាយដល់គ្រឹះស្ថាន

ឧត្តមសិក្សា ស្ថាប័ននានា និងមហាជន និង ដោយឡែកសំរាប់សម្របសម្រួលនិងសុខដុមនីយកម្ម ការងារហ្វឹកហ្វឺន ជាមួយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-សិក្សាទីផ្សារការងារនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម

-ផ្តល់យោបល់ និងកែលំអរបច្ចេកទេសគណនេយ្យនិងសវនកម្ម ។

**ប្រការ ៣** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីជន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារៈកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចម្លងជូន:</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង/ស្ថាប័នពាក់ព័ន្ធ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៣
-ឯកសារ/កាលប្បវត្តិ